**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

**គណៈកម្មការសុរិយោដីថ្នាក់ជាតិ**
លេខ ៖..១៧.........ជនស\គសជ

*រាជធានីភ្នំពេញ,ថ្ងៃទី០៦ ខែ ៥ ឆ្នាំ ២០១០*

# សេចក្តីណែនាំបន្ថែម
## ស្តីពី
## ការអនុវត្តប្រកាសលេខ ១១២ ជនស/ប្រក ស្តីពីគោលការណ៍ណែនាំ និង នីតិវិធីរបស់គណៈកម្មការសុរិយោដី

បន្ទាប់ពីគណៈកម្មការសុរិយោដីថ្នាក់ជាតិរួមជាមួយនឹងដៃគូអភិវឌ្ឍន៍គឺ អង្គការ GTZ ប្រចាំក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានធ្វើការសិក្សាវាយតម្លៃលើការងារដោះស្រាយទំនាស់ដីធ្លីរបស់គណៈកម្មការសុរិយោដីកន្លងមកឃើញថា មានចំណុចខ្វះខាតមួយចំនួនក្នុងនីតិវិធីនៃការដោះស្រាយវិវាទដីធ្លីរបស់គណៈកម្មការសុរិយោដីនៅឡើយ ហើយការខ្វះខាតនេះ គណៈកម្មការសុរិយោដីថ្នាក់ជាតិកំពុងសិក្សាដើម្បីបំពេញបន្ថែមជាបន្តបន្ទាប់។

ចំពោះមុខ ក្នុងគោលបំណងសម្រួលដល់ការអនុវត្តនីតិវិធីឲ្យកាន់តែមានប្រសិទ្ធភាព គណៈកម្មការសុរិយោដីថ្នាក់ជាតិសូមណែនាំដូចខាងក្រោម ៖

១-ករណីវិវាទពហុភាគី

-កម្មវត្ថុនៃបណ្តឹងទាមទារដីធ្លីធ្វើឡើងដើម្បីបំរើផលប្រយោជន៍សាធារណៈ ដែលករណីនេះ ភាគីវិវាទមានសិទ្ធិអាចជ្រើសរើសក្នុងចំណោមភាគីពាក់ព័ន្ធនឹងវិវាទនូវតំណាងផ្ទេរសិទ្ធិម្នាក់ ឬច្រើននាក់ ដើម្បីដាក់ពាក្យបណ្តឹង និងដំណើរការដោះស្រាយតាមនីតិវិធីរបស់គណៈកម្មការសុរិយោដី។

-កម្មវត្ថុនៃបណ្តឹងទាមទារដីធ្លីធ្វើឡើងដើម្បីបំរើផលប្រយោជន៍ឯកជនម្នាក់ៗ ករណីនេះ ភាគីវិវាទនីមួយៗត្រូវដាក់ពាក្យបណ្តឹងដោយផ្ទាល់ ដូចនីតិវិធីរបស់គណៈកម្មការសុរិយោដីដែលបានអនុវត្តកន្លងមក។

២-កំណត់រយៈពេល ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីភាគីទទួលបានសេចក្តីជូនដំណឹង ឬទម្រង់បែបបទច្រានចោលពាក្យបណ្តឹង ភាគីវិវាទមានសិទ្ធិប្តឹងជំទាស់នឹងការច្រានចោលនោះ។

អាស័យដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន ក្រុងភ្នំពេញ
Tel : (855) 023 215 659-215 660 , Fax : (855) 023 215 277 , e-mail : im. c . lim. @ Camnet. Com. Kh

៣-ត្រូវពង្រឹងបន្ថែមទៀត ការជូនដំណឹងដល់ភាគីវិវាទនូវសិទ្ធិក្នុងការជ្រើសរើសជំនួយការភាគី ជាពិសេសត្រូវសហការជិតស្និទ្ធជាមួយសង្គមស៊ីវិល ឬអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តការងារនេះឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ។

៤-ត្រូវពង្រឹងបន្ថែមទៀតនូវការស៊ើបអង្កេត និង ការធ្វើសេចក្ដីសន្និដ្ឋានលើសំណុំរឿងវិវាទនីមួយៗឲ្យបានច្បាស់លាស់មុននឹងសម្រេចធ្វើការច្រានចោល។ ពិសេសជាងនេះទៅទៀត បន្ទាប់ពីការច្រានចោលករណីបណ្ដឹងណាមួយរួចហើយ គណៈកម្មការសុរិយោដីគ្រប់ថ្នាក់ត្រូវតែច្បាស់លាស់ថា ការសម្រេចច្រានចោលបណ្ដឹងនោះត្រូវបានជូនដំណឹងឬបានប្រគល់ទម្រង់បែបបទច្រានចោលបណ្ដឹងដោយផ្ទាល់ដល់គូភាគីវិវាទផងដែរ ។ រាល់ការជូនដំណឹង ឬ ការប្រគល់ ទទួលទម្រង់បែបបទច្រានចោលត្រូវមានឯកសារបញ្ជាក់ ដើម្បីតម្កល់ទុកក្នុងសំណុំរឿងផ្លូវការ ។

នាយកខុទ្ទកាល័យ ប្រធានគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និង ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តសេចក្ដីណែនាំបន្ថែមនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ**

អ៊ឹម ឈុនលឹម

**<u>ចម្លងជូន</u>**

-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
-សាលារាជធានី ខេត្ត
"ដើម្បីជូនជ្រាប"
-ឯកសារ-កាលប្បវត្តិ